# នីតិវិធីដោះស្រាយសំណងខាងក្រោមអនុវត្តចំពោះតែបណ្ណសន្យារ៉ាប់រងភារៈទទួលខុសត្រូវជាសាធារណៈ

ក្នុងករណីមានហេតុការណ៍ណាមួយដែលអាចបណ្តាលឱ្យមានការទាមទារសំណង

↓

លោកអ្នកត្រូវជូនដំណឹងមក **ប្រូស្វរ** ជាបន្ទាន់តាមដែលអាចធ្វើទៅបាន តាមរយៈ ការជូនដំណឹងដោយផ្ទាល់ ទូរស័ព្ទទាន់ហេតុការណ៍ សារអេឡិចត្រូនិក លិខិតជាលាយលក្ខណ៍អក្សរ ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀត

↓

**ប្រូស្វរ** នឹងតែងតាំងមេធាវី/ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង

**បាទ/ចាស**

**ប្រូស្វរ** នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការតែងតាំងមេធាវី/ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងទៅកាន់លោកអ្នក

↓

**ប្រូស្វរ** នឹងផ្ញើជូនលោកអ្នកនូវទម្រង់បែបបទក្នុងការទាមទារសំណង និងផ្តល់បញ្ជីឯកសារតម្រូវក្នុងរយៈពេល **២៤ ម៉ោង** បន្ទាប់ពីទទួលបានការជូនដំណឹង

↓

មេធាវី/ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងដែលត្រូវបានតែងតាំងនឹងទាក់ទងលោកអ្នក/តតិយជនទាមទារសំណងដើម្បីត្រួតពិនិត្យការបាត់បង់ ឬការខូចខាត និងស្នើសុំឯកសារពាក់ព័ន្ធផ្សេងៗ

↓

មេធាវី/ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងដែលត្រូវបានតែងតាំងនឹងពិភាក្សាជាមួយលោកអ្នក/តតិយជនទាមទារសំណង និងរៀបចំរបាយការណ៍នៃការខូចខាតសម្រាប់ជាឯកសារមូលដ្ឋានក្នុងការទូទាត់សំណង

**ទេ**

មន្ត្រីដោះស្រាយសំណងរបស់ **ប្រូស្វរ** នឹងទាក់ទងលោកអ្នកដើម្បីស៊ើបអង្កេត និងវាយតម្លៃហានិភ័យដែលបានកើតឡើង

↓

**ប្រូស្វរ** នឹងផ្ញើជូនលោកអ្នកនូវទម្រង់បែបបទក្នុងការទាមទារសំណង និងផ្តល់បញ្ជីឯកសារតម្រូវក្នុងរយៈពេល **២៤ ម៉ោង** បន្ទាប់ពីទទួលបានការជូនដំណឹង

↓

អ្នកស៊ើបអង្កេតហានិភ័យរបស់ **ប្រូស្វរ** នឹងរៀបចំរបាយការណ៍នៃការខូចខាតសម្រាប់ជាឯកសារមូលដ្ឋានក្នុងទូទាត់សំណង

↓

ករណីការស្នើសុំទាមទារសំណង មិនមានឯកសារគ្រប់គ្រាន់ **ប្រូស្វរ** នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬតាមរយៈសារអេឡិចត្រូនិកទៅកាន់លោកអ្នក/តតិយជនទាមទារសំណងក្នុងរយៈពេល**៣ ថ្ងៃ** នៃថ្ងៃធ្វើការ

↓

បន្ទាប់ពីទទួលបានរបាយការណ៍ពីមេធាវី/ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង និង/ឬឯកសារគ្រប់គ្រាន់ **ប្រូស្វរ/មេធាវី** នឹងឆ្លើយតបទៅកាន់លោកអ្នក/តតិយជនទាមទារសំណងជាលាយលក្ខណ៍អក្សរអំពីការសម្រេចផ្តល់សំណង ឬការបដិសេធការទទួលខុសត្រូវ ក្នុងរយៈពេល **១៥ ថ្ងៃ** នៃថ្ងៃធ្វើការ

**ការសម្រេចផ្តល់សំណង**

**ប្រូស្វរ/មេធាវីត្រូវបានតែងតាំង** នឹងចេញលិខិតបញ្ជាក់ពីការធ្វើសំណង និងលិខិតបញ្ជាក់ការទាមទារសំណងជូនលោកអ្នក/តតិយជនទាមទារសំណងដើម្បីចុះហត្ថលេខាឯកភាពទទួលយកសំណង

↓

**ប្រូស្វរ** នឹងទូទាត់សំណងជូនលោកអ្នក/តតិយជនទាមទារសំណងក្នុងរយៈពេល **៣ ថ្ងៃ** នៃថ្ងៃធ្វើការ បន្ទាប់ពីការឯកភាពទទួលយកសំណងចំពោះការទូទាត់ទាំងស្រុង ឬក្នុងរយៈពេលដូចបានកំណត់នៅក្នុងកិច្ចព្រមព្រៀងទទួលយកសំណងរវាង **ប្រូស្វរ** និងអ្នកទាមទារសំណង/តតិយជនទាមទារសំណងចំពោះការទូទាត់សំណងជាដំណាក់កាល

**ការបដិសេធការទទួលខុសត្រូវ**

**ប្រូស្វរ/មេធាវីត្រូវបានតែងតាំង** នឹងផ្ញើលិខិតបដិសេធសំណងទៅកាន់អ្នកទាមទារសំណង/តតិយជនទាមទារសំណងដោយបញ្ជាក់អំពីមូលហេតុសម្រាប់ការបដិសេធសំណង

<u>កំណត់សម្គាល់</u>

- មិនមានការព្រមទទួលខុសត្រូវ ការផ្តល់ជូន ការសន្យា ការធ្វើសំណង ឬការចំណាយណាមួយត្រូវបានធ្វើឡើងក្នុងនាម ឬ ជំនួស លោកអ្នក ដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនយើងខ្ញុំឡើយ។

PROSUR INSURANCE PLC.

## The claim procedure below applies to Public Liability Insurance

In the event of an incident that may give rise to a claim

You must give notice to Prosur immediately by walk-in, claim hotline contact, email, written letter or other communication means

Prosur will appoint a Lawyer/Loss Adjuster

**Yes**

- Prosur will send a written notice of the appointment of the Lawyer/Loss Adjuster to you
- Prosur will send claim form and a list of required documents to you within **24 hours** after receiving notification
- The appointed lawyer/loss adjuster will contact you/3rd party Claimant to assess the loss and request for relevant documents from you/3rd party Claimant
- The appointed lawyer/loss adjuster will discuss with you/3rd party Claimant and prepare the loss report for Prosur for claim settlement

**No**

- Prosur's Claims Officer will contact you to assess the loss
- Prosur will send claim form and a list of required documents to you within **24 hours** after receiving notification
- In-house professional Claims Officer will prepare the loss report for claim settlement

Prosur will send a written notice / an email to you/3rd party Claimant within **03 working days** in case that supporting document is insufficient

Upon receipt of appointed lawyer's or loss adjuster's report/in-house loss report and /or full documents, Prosur or the appointed lawyer will send a written letter to you/3rd party Claimant within **15 working days** in respect of Offer of Settlement or Repudiation of Liability

**Offer of Settlement**

- Prosur/the appointed lawyer will issue Offer Letter and Discharge Voucher to you or 3rd party Claimant for agreement and signature
- Prosur will make claim payment to you/3rd party Claimant within **03 working days** upon of acceptance of the Offer of Settlement for full settlement or within the period specified in settlement agreement between Prosur and the claimant/3rd party Claimant for installment settlement

**Repudiation of Liability**

- Prosur/the appointed lawyer will send repudiation letter to the claimant/ 3rd party Claimant stating reason (s) for the repudiation

**<u>Note:</u>**

- No admission, offer, promise, payment or indemnity shall be made or given by or on behalf of you without our prior written consent.